# គណបក្ស សម រង្សុី

SAM RAINSY PARTY

PARTI SAM RAINSY

សីលធម៌ សន្តិធម៌ យុត្តិធម៌

លេខ :...056... អ.គស

## អគ្គលេខាធិការគណបក្ស សម រង្សុី
## សូមជំរាបជូន
## ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

យោងពីរឿង៖ ស្ថានភាពសុវត្ថិភាពនយោបាយ ឧក្រិដ្ឋកម្ម ទាក់ ធនធ្ងន់ធ្ងរក្នុងភូមិត្រពាំងកន្ទ ឃុំមេមត់ ស្រុកមេមត់ ខេត្ត កំពង់ចាម ដែលបានតំរូវកំហែង បំភិតបំភ័យប្រជាពលរដ្ឋនៅក្នុងភូមិ

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមសហរដ្ឋមន្ត្រីមេត្តាជ្រាបថា ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០១ រដ្ឋបាលភូមិត្រពាំងកន្ទ ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ឈ្មោះ សោម ខាន់ បានធ្វើសកម្មភាពតំរូវកំហែងមកលើប្រជាពលរដ្ឋនៅភូមិត្រពាំងកន្ទ ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ដែលពាក់អ្នក និងអាវដែលមានផ្ទាក់សញ្ញាគណបក្ស សម រង្សុី ដោយបង្ខំប្រជាពលរដ្ឋទាំងនោះឲ្យស្រឡាញ់អ្នក និងអាវដែលមានផ្ទាក់សញ្ញាគណបក្សសម រង្សុី ទៅតាត់ដើម្បីធ្វើការដុតបំផ្លាញចោល ។

លុះដល់ព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០១ វេលាម៉ោង៩ព្រឹក បុគ្គលឈ្មោះ សោម ខាន់ ដដែលនេះ បានកាន់ក្លាក់អ្នកផ្ទាក់សញ្ញាគណបក្ស សម រង្សុី ពីឈ្មោះច្រូច យកមកតាប់ចិញ្ច្រាំនឹងចងនៅចំពោះមុខប្រជាពលរដ្ឋដែលកំពុងលើកដីលុបល្ង ។ លើសពីនេះទៀត បុគ្គលឈ្មោះ សោម ខាន់ នេះបានប្រើសំដីគំរាមប្រជាពលរដ្ឋដែលគាំទ្រគណបក្ស សម រង្សុី ដោយនិយាយថា " ថ្ងៃណាមួយពួកយ្មៀងតង់ត្រូវនឹងតស៊ីអ្នកឲ្យជាមិនខាន " ។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាចាត់វិធានការទប់ស្កាត់ចំពោះអំពើគំរាមកំហែងបំភិតបំភ័យនេះ ហើយដាក់វិន័យតាមច្បាប់ចំពោះជនឈ្មោះ សោម ខាន់ នេះ ដើម្បីបង្ហាញមតិជាតិ និងអន្តរជាតិឲ្យឃើញថា ប្រទេសកម្ពុជាពិតជាស្ថិតក្នុងគន្លងប្រជាធិបតេយ្យ និងជានីតិរដ្ឋ ច្បាស់លាស់មែន ។

សូមឯកឧត្តម សហរដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

ធ្វើនៅទីក្រុងភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១

ហ៊ីង ចាន់ធី

ចំលងជូន៖
- ទីស្នាក់ការយោធាភូមិភាគ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា
- អង្គការសិទ្ធិមនុស្សនានាប្រចាំនៅកម្ពុជា
- អង្គទូតនានាប្រចាំនៅកម្ពុជា
- សារព័ត៌មានជាតិ និងអន្តរជាតិ